Cambodian / Khymer

CASA Forum
Victorian Centres Against Sexual Assault

# Victorian Centre Against Sexual Assault

# មជ្ឈមណ្ឌលប្រឆាំងនូវអំពើរំលោភតាមផ្លូវភេទនៅរដ្ឋវិចតូរា

សន្លឹកបណ្ណីនេះបានសរសេរឡើងដើម្បីអោយអស់លោកអ្នកដឹងអំពីកិច្ចបំរើផ្តល់ជូន នៅមជ្ឈមណ្ឌលដែលប្រឆាំងនូវអំពើរំលោភតាមផ្លូវភេទនៅក្នុងរដ្ឋវិចតូរា។

## អ្វីទៅដែលជាអំពើរំលោភតាមផ្លូវភេទ?

អំពើរំលោភតាមផ្លូវភេទគឺជាឥរិយាបទណាមួយនៃធម្មជាតិផ្លូវភេទ ដែលធ្វើអោយលោកអ្នកទទួលអារម្មណ៍មិនសុខស្រួល, រន្ធត់ ខ្លាច, បំភ័យឬគំរាមកំហែង។ វាជាឥរិយាបទផ្លូវភេទដែលលោកអ្នកមិនបានយល់ព្រមជាមួយ, នៅពេលណាដែលមនុស្សណាម្នាក់រួមទាំងស្វាមីប្រើការបង្ខិតបង្ខំផ្នែករាងកាយនិងផ្លូវចិត្ត។ រឿងនេះអាចរួមទាំងការលូកលាន់ខាងផ្លូវភេទ, ប៉ះពាល់ និងការចាប់រំលោភ។

## កិច្ចបំរើដែលមានផ្តល់ជូន

- កិច្ចបំរើពេលមានអាសន្ន ឬកិច្ចបំរើមើលថែរក្សានៅពេលកើតមានវិបត្តិ – កិច្ចបំរើពេលមានអាសន្នគឺមានផ្តល់ជូន ២៤ម៉ោងដល់លោកអ្នកប្រសិនបើលោកអ្នកត្រូវបានគេរំលោភតាមផ្លូវភេទក្នុងពេលថ្មីៗ
- ការពិភាក្សាផ្តល់យោបល់ និងការគាំទ្រ – នេះបានសេចក្តីថានឹងអាចជជែកព្រមទាំងត្រូវបានគេស្តាប់នៅក្នុងទីកន្លែងដែលមានសុវត្ថិភាពនិងភាពសម្ងាត់។
- ការគាំទ្រ – នេះបានសេចក្តីថាលោកអ្នកនឹងត្រូវគេជំរាបអោយដឹងនូវសិទ្ធិរបស់លោកអ្នកទាក់ទងទៅនិងផ្នែកពេទ្យ, ច្បាប់ និងគាំទ្រផ្គត់ផ្គង់ពត៏មានដល់សង្គមគ្រួសារ,មិត្តភក្ត។
- បកប្រែភាសា – មជ្ឈមណ្ឌលប្រឆាំងនូវអំពើរំលោភតាមផ្លូវភេទអាចស្នើកិច្ចបកប្រែភាសាដើម្បីអោយលោកអ្នកអាចនិយាយជាភាសាលោកអ្នកផ្ទាល់បាន។

## របៀបទាក់ទងមជ្ឈមណ្ឌលប្រឆាំងនូវអំពើរំលោភតាមផ្លូវភេទ

ទូរស័ព្ទលេខ ១៨០០ ៨០៦ ២៩២ សេវា ២៤ ម៉ោង។